**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**Kingdom of Cambodia**
**Nation Religion King**

**ក្រសួងរ៉ែ និងថាមពល**
**Ministry of Mines and Energy**
លេខ: ០២៧.១៩.ឋាប.ស៊ីណ

ថ្ងៃពុធ ១៣រោច ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី២៨ខែសីហា ឆ្នាំ២០១៩

# សេចក្ដីជូនដំណឹង
## ស្ដីពី
## កាលបរិច្ឆេទនិងមណ្ឌលប្រឡង ចំពោះបេក្ខជនដែលបានដាក់ពាក្យសុំសិទ្ធិប្រឡង ប្រជែងជ្រើសរើសឱ្យចូលបម្រើការងារ ក្នុងក្របខណ្ឌក្រសួងរ៉ែនិងថាមពល ឆ្នាំ២០១៩

គណៈកម្មការរៀបចំការប្រឡង សូមជូនដំណឹងដល់បេក្ខជន ដែលបានដាក់ពាក្យសុំសិទ្ធិប្រឡងប្រជែងជ្រើសរើសឱ្យចូលបម្រើការងារក្នុងក្របខណ្ឌក្រសួងរ៉ែនិងថាមពលសម្រាប់ឆ្នាំ២០១៩ ឱ្យបានជ្រាបថា កាលបរិច្ឆេទ និង មណ្ឌលប្រឡង មានដូចខាងក្រោម៖

I. **កាលបរិច្ឆេទប្រឡង**

***នៅថ្ងៃសៅរ៍ ទី០៧ ខែកញ្ញា ឆ្នាំ២០១៩*** តាមពេលវេលាដូចខាងក្រោម៖

| | | | |
|---|---|---|---|
| **ពេលព្រឹក៖** | ម៉ោង ៧:៣០ នាទី ដល់ម៉ោង ៩:០០ នាទី | វិញ្ញាសាវប្បធម៌ទូទៅ | មេគុណ ១ |
| | ម៉ោង ៩:៣០ នាទី ដល់ម៉ោង ១១:០០ នាទី | វិញ្ញាសាភាសាអង់គ្លេសទូទៅ | មេគុណ ១ |
| **ពេលរសៀល៖** | ម៉ោង ១៤:០០ នាទី ដល់ម៉ោង ១៧:០០ នាទី | វិញ្ញាសាជំនាញបច្ចេកទេស | មេគុណ ២។ |

II. **មណ្ឌលប្រឡង**

***នៅសាលាបឋមសិក្សាព្រះនរោត្តម។***

អាស្រ័យហេតុនេះ សូមបេក្ខជនទាំងអស់ជ្រាបជាព័ត៌មាន និង សូមមកពិនិត្យឈ្មោះ លេខតុ និងលេខបន្ទប់ប្រឡង នៅទីស្ដីការក្រសួងរ៉ែនិងថាមពល ឬសាលាបឋមសិក្សាព្រះនរោត្តម ឬលើគេហទំព័ររបស់ក្រសួង នៅថ្ងៃសុក្រ ទី០៦ ខែកញ្ញា ឆ្នាំ២០១៩ ។

*បញ្ជាក់៖* -បេក្ខជនត្រូវមកឱ្យដល់មណ្ឌលប្រឡង ឱ្យបានមុនម៉ោងកំណត់យ៉ាងតិច ៣០ នាទី។

**ជ.គណៈកម្មការរៀបចំការប្រឡង**
**ប្រធាន**

ស៊ុយ ធីម៉ិច

លេខ ៧៩-៨៩ ផ្លូវប៉ាស្ទ័រ (៥១) សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥) ២៣ ២១៩ ៥៧៤ ទូរសារ (៨៥៥) ២៣ ២១៩ ៥៨៤
#79-89, Pasteur Street(51), Sangkat Phsar Thmey3, Khan Daun Penh, Phnom Penh. Tel: (855) 23 219 574 Fax: (855) 23 219 584 www.mme.gov.kh info@mme.gov.kh